# ប្រធានសិទ្ធិមនុស្ស អ.ស.ប គូសបញ្ជាក់ថា សុវត្ថិភាពអ្នកសារព័ត៌មាន មានសារៈសំខាន់សម្រាប់សង្គមប្រជាធិបតេយ្យដែលរស់រវើក



រូបភាពដោយ៖ Jean-Marc Ferré

ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ - ប្រធានសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានប្រកាសនៅថ្ងៃនេះ ថា វិជ្ជាជីវៈសារព័ត៌មាន "រឹងមាំ អង់អាចក្លាហាន និងឯករាជ្យ" មានសារៈសំខាន់ណាស់ ទោះជាក្នុងសង្គមប្រជាធិបតេយ្យណាក៏ដោយ ដោយគូសបញ្ជាក់ពីតម្រូវការក្នុងការធានាសុវត្ថិភាពដល់សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយ ដែលបាន និងកំពុងស្ថិតក្រោមការវាយប្រហារ ការយាយីរំខាន និងការបំភិតបំភ័យកាន់តែខ្លាំងឡើង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

"សុវត្ថិភាពអ្នកសារព័ត៌មាន ពិតជាមានសារៈសំខាន់ណាស់ ចំពោះសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់យើងគ្រប់គ្នា ក៏ដូចជា សិទ្ធិក្នុងការអភិវឌ្ឍន៍ នេះបើតាម ប្រសាសន៍របស់លោកស្រី ណាវីភីឡៃ ឧត្តមស្នងការសិទ្ធិមនុស្ស នៅក្នុងអំឡុងពេលនៃការពិភាក្សាជាក្រុមស្តីពីបញ្ហានេះ ដែលបានឡើងនៅទីក្រុងហ្សឺណែវ។

ទោះជាយ៉ាងណាក៏ដោយ លោកស្រី បានកត់សំគាល់ថា នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកសារព័ត៌មាន និងសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ បាននិងកំពុងក្លាយជាគោលដៅនៃអំពើហិង្សា។ មានអ្នកព័ត៌មានច្រើនជាងមួយពាន់នាក់ ត្រូវបានគេសម្លាប់ ចាប់តាំងពីឆ្នាំ១៩៩២ មក ជាបច្ច័យផ្ទាល់នៃវិជ្ជាជីវៈរបស់ខ្លួន។ ម្យ៉ាងវិញទៀត នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ ក្នុងចំណោមឆ្នាំ ដែលអ្នកសារព័ត៌មានបានស្លាប់ច្រើន

ជាងឆ្នាំណាៗទាំងអស់ ហើយយ៉ាងហោចណាស់ក៏មានអ្នកសារព័ត៌មានចំនួន១៥ នាក់ដែរ ដែលត្រូវបាន សម្លាប់ចាប់តាំងពីដើមឆ្នាំនេះ។

លោកស្រីបានមានប្រសាសន៍ថា៖ " នៅក្នុងរដ្ឋជាច្រើន ជនល្មើសនៃការវាយប្រហារទាំងនេះ ស្ទើរតែស្ថិតនៅជានិទណ្ឌភាព " ។

អ្នកសារព័ត៌មានជាច្រើនទៀត បានប្រឈមមុខនឹងអំពើហិង្សា ការយាយីរំខាន និងការបំភិតបំភ័យ រាប់ទាំងការចាប់ពង្រត់ ការឃុំខ្លួនដោយបំពាន ការបាត់ខ្លួនដោយបង្ខំ ការបណ្តេញចេញ ការឈ្លបមើលដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទោកបន្ទាប និងអំពើហិង្សាផ្លូវភេទប្រឆាំងនឹងអ្នកសារព័ត៌មានជាស្ត្រីភេទ។

ការយល់ដឹងជាអន្តរជាតិមានការកើនឡើង នៅក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ អំពីភាពញយដងដែលអ្នកសារព័ត៌មាន ត្រូវបានវាយប្រហារដោយសារតែការងាររបស់ខ្លួន និងតម្រូវឲ្យមានការធានាការពារកាន់តែច្រើនថែមទៀត លោកស្រីឧត្តមស្នងការ បានកត់សំគាល់ដូច្នេះ។

ស្ថាប័នសំខាន់ៗរបស់អង្គការសហប្រជាជាតិ រាប់ទាំងក្រុមប្រឹក្សាសន្តិសុខ មហាសន្និបាត និងក្រុមប្រឹក្សាសិទ្ធិមនុស្ស ទាំងអស់គ្នា បានអនុម័តសេចក្តីសម្រេចចិត្ត ថ្កោលទោសការវាយប្រហារទាំងនេះ ហើយអំពាវនាវដល់រដ្ឋភាគីនានាឲ្យធានាបរិស្ថានមួយប្រកបដោយសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន។

លើសពីនេះទៀត នៅឆ្នាំ២០១២ អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ (UNESCO) បានបង្កើតផែនការសកម្មភាព អ.សប ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព ដែលបច្ចុប្បន្នកំពុងត្រូវបានដាក់ឲ្យអនុវត្តសាកល្បងនៅក្នុងប្រទេសចំនួនប្រាំគឺ អ៊ីរ៉ាក់ នេប៉ាល់ ប៉ាគីស្ថាន ស៊ូដង់ភាគខាងត្បូង និងទុយណេស៊ី។ គំនិតផ្តួចផ្តើមនេះ ត្រូវបានធ្វើផងដែរដោយអង្គការមួយចំនួននៅក្នុងតំបន់។

ជាពិសេស លោកស្រី ភីឡៃ បានមានប្រសាសន៍ថា ត្រូវតែមានជាការប្តេជ្ញាចិត្តខាងនយោបាយច្បាស់លាស់ ដើម្បីធ្វើឲ្យប្រាកដថា អ្នកសារព័ត៌មាន អាចអនុវត្តការងាររបស់ខ្លួនដោយសុវត្ថិភាព។ ភ្ជាប់ទៅនឹងបញ្ហានេះ គឺជាសំនួរ អំពីអ្នកដែលអាចត្រូវបានចាត់ទុកថាជាអ្នកសារព័ត៌មាន។

"ពីទស្សនៈវិស័យសិទ្ធិមនុស្ស វាច្បាស់ណាស់ដែលថា៖ បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារពេញលេញនូវសិទ្ធិមនុស្សរបស់ខ្លួន ទោះជារដ្ឋទទួល ឬមិនទទួលស្គាល់ពួកគេថាជា "អ្នកសារព័ត៌មាន" ក្តី ទោះជាពួកគេជាអ្នកយកព័ត៌មានវិជ្ជាជីវៈ ឬអ្នកសារព័ត៌មានជាប្រជាពលរដ្ឋធម្មតា" ក្តី ទោះជាពួកគេជាអ្នកសារព័ត៌មាន មាន ឬមិនមានសញ្ញាប័ត្រវិជ្ជាជីវៈសារព័ត៌មានក្តី ទោះជាពួកគេធ្វើសេចក្តីរាយការណ៍លើបណ្តាញអនឡាញ ឬក្រៅបណ្តាញអនឡាញក្តី"។

ក្នុងលក្ខខណ្ឌនៃការអនុវត្តល្អ លោកស្រីឧត្តមស្នងការ បានលើកពីការបង្កើតយន្តការព្រមានដំបូង និងយន្តការឆ្លើយតបឆាប់រហ័ស ដើម្បីផ្តល់ឲ្យអ្នកសារព័ត៌មាន និងតួអង្គនៃប្រព័ន្ធផ្សព្វផ្សាយដទៃទៀត នូវលទ្ធភាពជួបភ្លាមៗជាមួយអាជ្ញាធរ និងវិធានការបង្ការ នៅពេលដែលពួកគេត្រូវបានគំរាមកំហែង។

លោកស្រី ភីឡៃ បានសង្កត់ធ្ងន់ថា "ប្រការសំខាន់បំផុតនោះគឺ រដ្ឋនានា ត្រូវប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព" " រាល់សកម្មភាពហឹង្សា ដែលបានប្រព្រឹត្តលើអ្នកសារព័ត៌មាន ដែលមិនបានធ្វើការស៊ើបអង្កេត និង

ដាក់ទោសទណ្ឌ គឺជាការបើកចំហរឲ្យមានអំពើហឹង្សាបន្ថែមទៀត។

"ការធានាឲ្យមានគណនេយ្យភាព ចំពោះការវាយប្រហារប្រឆាំងនឹងអ្នកសារព័ត៌មាន គឺជាសមាសធាតុមួយដ៏សំខាន់ក្នុងការបង្ការការវាយប្រហារនាពេលអនាគត" លោកស្រីបានបញ្ជាក់បន្ថែមដូច្នេះ។ "ការខកខានមិនបានធ្វើដូចនេះ អាចត្រូវបានបកស្រាយថាជាការអត់ឱន ឬការយល់ព្រមឲ្យមានអំពើហិង្សា។ ការស៊ើបអង្កេត និងការកាត់ទោស រាល់ការវាយប្រហារប្រឆាំងនឹងអ្នកសារព័ត៌មាន តាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុកមួយដែលដំណើរការល្អ និងមានប្រសិទ្ធិភាព គឺជាការចាំបាច់ ហើយត្រូវតែជួសជុលសំណងដល់ជនរងគ្រោះ" ។

ការលើកកំពស់សុវត្ថិភាពអ្នកសារព័តមាន និងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ចំពោះអ្នកដែលវាយប្រហារពួកគេ គឺជាសមាសធាតុដ៏សំខាន់ ក្នុងកម្មវិធីរបស់អង្គការយូណេស្កូ គាំទ្រដល់សេរីភាពសារព័ត៌មាន។ ទីភ្នាក់ងារដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស បានប្តេជ្ញាចិត្តលើកកំពស់សេរីភាពសារព័ត៌មាន និងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ទាំងនៅលើបណ្តាញអនឡាញ ឬនៅក្រៅបណ្តាញអនឡាញ" តាមរយៈសកម្មភាពផ្សេងៗ រាប់ទាំងការលើកកំពស់ការយល់ដឹង ពង្រឹងភាពជាដៃគូ និងការសម្របសម្រួលនៃផែនការសកម្មភាព អស.ប ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន។

ថ្លែងទៅកាន់អង្គប្រជុំទាំងមូល Getachew Engida នាយរងអង្គការយូណេស្កូ បានគូសបញ្ជាក់ពីតម្រូវការឲ្យមានការប្តេជ្ញាចិត្តខាងនយោបាយមួយពិតប្រាកដ ពីមេដឹកនាំទាំងឡាយ ក៏ដូចជាការកែសម្រួលនៅក្នុងប្រព័ន្ធច្បាប់ ដើម្បីធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។